# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា


កាវិយាល័យផ្នែក កម្មវិធីសិក្សា និងការវាយតម្លៃ

440 North Broad Street, Suite 251
Philadelphia, PA 19130

Donna Runner
នាយិការង ស្តីទី

ទូរស័ព្ទ៖ ២១៥-៤០០-៤២១០
ទូរសារ៖ ២១៥-៤០០-៤២១២


ជូនចំពោះ មាតាបិតា/អាណាព្យាបាល របស់សិស្សានុសិស្សថ្នាក់ទី៧ និងថ្នាក់ទី៨ បច្ចុប្បន្ន៖

ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា បានអនុវត្តការប្រឡង ឃីស្តូន (Keystone) ថ្មី ជំនួសប្រព័ន្ធនៃការវាយតម្លៃសាលារបស់រដ្ឋផិនស៊ីលវេញ៉ា (PSSA) សម្រាប់សិស្សថ្នាក់ទី១១។ ការប្រឡង ឃីស្តូន គឺជាការវាយតម្លៃនៅពេលរៀនចប់មុខវិជ្ជា រៀបចំឡើងដើម្បីវាយតម្លៃការស្ទាត់ជំនាញក្នុងការសិក្សាមុខវិទ្យាសំខាន់ៗ។ ចាប់ផ្តើមជាមួយសិស្សានុសិស្សដែលនឹងបញ្ចប់ការសិក្សានៅឆ្នាំ២០១៧ (សិស្សានុសិស្សថ្នាក់ទី៩ បច្ចុប្បន្ន) សិស្សានុសិស្សត្រូវបង្ហាញឲ្យឃើញនូវភាពស្ទាត់ជំនាញចំពោះមុខវិទ្យា ពិជគណិត១ អក្សរសាស្រ្ត និងជីវវិទ្យា (Algebra I, Literature, Biology) នៃការប្រឡង ឃីស្តូន ទើបអាចបញ្ចប់ការសិក្សាបាន។ ដោយមូលហេតុនេះហើយ តម្រូវការថ្មីនេះនឹងពាក់ព័ន្ធដល់ការបញ្ចប់ការសិក្សារបស់កូនលោកអ្នកពីវិទ្យាល័យ។

សិស្សានុសិស្សដែលបានចុះឈ្មោះរៀនមុខវិទ្យាដែលទាក់ទងនឹង ឃីស្តូន (ពិជគណិត១/Algebra I អង់គ្លេស២/English 2 ជីវវិទ្យា/Biology) ត្រូវគេតម្រូវឲ្យប្រឡង (ពិជគណិត១ អក្សរសាស្រ្ត និងជីវវិទ្យា) របស់ ឃីស្តូន នៅពេលរៀនចប់មុខវិជ្ជា។ សិស្សានុសិស្សភាគច្រើនដែលរៀនថ្នាក់ទី៧ និងទី៨ ក្នុងពេលបច្ចុប្បន្ននេះ មិនរៀនមុខវិទ្យាដែលទាក់ទងនឹង ឃីស្តូន ទេ រហូតដល់ពេលពួកគេចូលរៀននៅវិទ្យាល័យ ដូច្នេះហើយពួកគេមិនបាច់ប្រឡង ឃីស្តូន ទេនៅឆ្នាំនេះ។ ទោះជាដូច្នេះក៏ដោយ *បើសិនជាបច្ចុប្បន្ននេះ កូនរបស់លោកអ្នកបានចុះឈ្មោះរៀន ពិជគណិត១ ពេញឆ្នាំ* ពួកគេត្រូវប្រឡង ពិជគណិត១ សម្រាប់ ឃីស្តូន នៅចុងឆ្នាំ។

បើសិនជាសិស្សានុសិស្សប្រឡង ឃីស្តូន ធ្លាក់ លើកទីមួយ ពួកគេអាចមានឱកាសប្រឡងជាច្រើនដងទៀត មុនពេលពួកគេបញ្ចប់ការសិក្សា។ ទោះជាដូច្នេះក៏ដោយ នៅខែមិថុនានៃឆ្នាំបញ្ចប់ការសិក្សារបស់ពួកគេពីវិទ្យាល័យ ពួកគេ**ត្រូវ**ប្រឡងឲ្យជាប់ មុខវិទ្យាទាំងបី របស់ ឃីស្តូន។

បើសិនជាលោកអ្នកមានសំណួរអ្វីអំពីការប្រឡង ឃីស្តូន សូមទាក់ទង assessment@philasd.org។